**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ០៣៦ សព្វក

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី ស្ថានភាពពលរដ្ឋភៀសសឹក ផលប៉ះពាល់លើតំបន់ស៊ីវិល**
**គិតពីម៉ោង៦ព្រឹក ថ្ងៃទី៣០ ដល់ម៉ោង៦ព្រឹក ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦**
**និងគោលជំហរក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិជ្រាបថា ចាប់ពីតាំងពីបទឈប់បាញ់រវាងកម្ពុជា និងថៃ ចូលជាធរមាន កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥មក ភាគីទាំងសងខាងពុំបានផ្ទុះអាវុធដាក់គ្នានោះឡើយ។ យ៉ាងណាក៏ដោយក្នុងរយៈពេលនេះ កម្ពុជាបានតាមដាន និងកត់ត្រាទុកជាបន្តបន្ទាប់ នូវសកម្មភាពមិនស្មោះត្រង់មួយចំនួនរបស់ភាគីថៃ។ ចំណែកផលប៉ះពាល់លើប្រជាពលរដ្ឋ និងតំបន់ស៊ីវិលកម្ពុជា ដែលបង្កឡើងដោយអំពើឈ្លានពាននោះ ក៏នៅតែជាបន្ទុកត្រូវដោះស្រាយជាអាទិភាពរបស់រាជរដ្ឋាភិបាល។ **ក្រសួងមហាផ្ទៃ** សូមផ្តល់ជូនបច្ចុប្បន្នភាពនៃសភាពការណ៍ជារួម គិតពីម៉ោង៦ព្រឹកថ្ងៃទី៣០ ដល់ម៉ោង៦ព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦នេះ ជាមួយនឹងការគូសបញ្ជាក់ជាថ្មីទៀតនូវគោលជំហរសំខាន់ៗ ដូចខាងក្រោម៖

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** គិតមកដល់ពេលនេះ ក្នុងចំណោមពលរដ្ឋភៀសសឹកសរុបជាង៦សែន៤ម៉ឺននាក់ មានប្រមាណជិត៥សែន៤ម៉ឺននាក់ ឬស្មើនឹង៨៣% បានវិលត្រឡប់ទៅលំនៅឋានវិញហើយ។ មានពលរដ្ឋភៀសសឹកចំនួន១១២.២៦២នាក់ទៀត កំពុងបន្តស្នាក់អាស្រ័យតាមជំរំនានា ក្នុងនោះស្ត្រីមានចំនួន៥៨.៨៤២នាក់ និងកុមារចំនួន៣៦.៧៤៤នាក់។

**២-ការបន្តបិទផ្អាកសេវាសាធារណៈជាមូលដ្ឋាន៖ ខេត្តឧត្តរមានជ័យ** មានសាលារៀន១៤ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព៧ បន្តបិទផ្អាក។ **ខេត្តបន្ទាយមានជ័យ** មានសាលារៀន៥ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១ បន្តបិទផ្អាក។ **ខេត្តព្រះវិហារ** មានសាលារៀន២៩ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ នៅបន្តបិទផ្អាក។ ក្នុងនាមជាសេនាធិការរាជរដ្ឋាភិបាល លើការងារគ្រប់គ្រងរដ្ឋបាលដែនដី **ក្រសួងមហាផ្ទៃ** បានកំពុងដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិសហការជាមួយក្រសួង-ស្ថាប័ននានា ដើម្បីជំរុញការស្តារជីវភាពប្រជាពលរដ្ឋ និងសេវាសាធារណៈដែលបានប៉ះពាល់ និងបិទផ្អាក ឱ្យវិលមករកភាពប្រក្រតីឡើងវិញជាបន្តបន្ទាប់ទៀត ជាពិសេសកិច្ចគាំពារ និងការគាំទ្រគ្រប់បែបយ៉ាងដល់ប្រជាពលរដ្ឋភៀសសឹកដែលពុំទាន់អាចវិលចូលទៅរស់នៅក្នុងផ្ទះសំបែងវិញបាន។

**៣-ការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** គិតចាប់ពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥មក **ការខូចខាតទ្រព្យសម្បត្តិឯកជន** សរុបរួមមាន ផ្ទះ៩៨០ខ្នង អគារស៊ីវិលឯកជន៧ អគារស្នាក់នៅ/សណ្ឋាគារ១០ ស្ថានីយប្រេង៤ ផ្សារឯកជន១ រថយន្ត៣៤គ្រឿង ម៉ូតូ១០គ្រឿង លានទិញជ័រឡង១ អគារឃ្លាំងទំនិញ១ បង្គោលអង់តែនទូរសព្ទ៣ អាងទឹកនិងប្រព័ន្ធទឹកស្អាត៦កន្លែង ជង្រុកស្រូវ១ និងសត្វពាហនៈ/សត្វព្រៃ២ក្បាល។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** សរុបរួមមាន សាលារៀន២៦ មន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ សំណង់អគារ៤២ វត្តអារាម១៩ សាលាឆទាន១ រូបសំណាក២ រថយន្ត១គ្រឿង ប្រាសាទបុរាណ៤ ស្ពាន៥ ផ្សារ១ ផ្លូវ៨៧ ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី១ទីតាំង និងបណ្តាញបញ្ជូនអគ្គិសនី៣កន្លែង ខណៈអាជ្ញាធរមូលដ្ឋានបន្តស្រង់ទិន្នន័យផលប៉ះពាល់បន្ថែម។

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា គោរពនិងគាំទ្រពេញទំហឹង ការបញ្ជាក់ច្បាស់ៗរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ថា កម្ពុជានឹងមិនធ្វើសម្បទាននូវអធិបតេយ្យ ឬសេចក្តីថ្លៃថ្នូររបស់ខ្លួនឡើយ។

ក្នុងន័យនេះ **ក្រសួងមហាផ្ទៃ** សូមប្រកាសគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលបានកំពុងអនុវត្តយ៉ាងពេញលេញតាមសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ របស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ និងកិច្ចព្រមព្រៀងទាំងឡាយ ដោយប្រកាន់ខ្ជាប់គោលការណ៍ច្បាប់អន្តរជាតិ ដែលភាគីថៃក៏បានដឹងដែរថា **ព្រំដែនមិនត្រូវបានកែប្រែដោយការប្រើប្រាស់កម្លាំងនោះឡើយ**។ ផ្ទុយទៅវិញ ភាគីថៃបានកំពុងធ្វើសកម្មភាពមួយចំនួនមិនស្របនឹងសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ របស់គណៈកម្មាធិការព្រំដែនទូទៅ ជាពិសេសការគោរពអធិបតេយ្យ និងបូរណភាពទឹកដី ធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាមួយចំនួននៅតែមិនអាចត្រឡប់ទៅលំនៅដ្ឋានវិញដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ដោយសារផ្ទះសំបែងពួកគាត់ត្រូវភាគីថៃដាក់របាំងជាមួយនឹងការគំរាមកំហែងសន្តិសុខ និងខ្លះទៀតត្រូវបានបំផ្លាញទាំងស្រុងតែម្តង ក្រោយការចូលជាធរមាននៃបទឈប់បាញ់។ ទង្វើនេះ បានផ្ទុយពីការប្តេជ្ញាចិត្តក្នុងសេចក្តីប្រកាសរួម ធ្វើឱ្យពលរដ្ឋភៀសសឹកត្រូវបន្តរស់នៅក្នុងជំរំបណ្តោះអាសន្ន ខណៈកុមាររាប់ពាន់នាក់ក៏នៅតែមិនអាចទៅសាលារៀនវិញបាន។ ទោះជាបែបនេះក្តី ក្នុងកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន នៅកោះសេប៊ូ ប្រទេសហ្វីលីពីន ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦ កម្ពុជាបានគូសបញ្ជាក់ឡើងវិញអំពីការបន្តប្តេជ្ញាយ៉ាងមុតមាំ និងស្មោះត្រង់ ដើម្បីបន្តរក្សា និងអនុវត្តបទឈប់បាញ់ និងសេចក្តីប្រកាសរួម ដោយសង្ឃឹមយ៉ាងមុតមាំថាលទ្ធផលនេះ នឹងមិនត្រឹមតែនាំដល់ការបញ្ឈប់អរិភាព ស្តារឡើងវិញនូវភាពស្ងប់ស្ងាត់ និងប្រក្រតីភាពតាមព្រំដែនប៉ុណ្ណោះទេ ប៉ុន្តែក៏ថែមទាំងជួយត្រួសត្រាយផ្លូវសម្រាប់ដំណោះស្រាយដ៏យុត្តិធម៌ និងយូរអង្វែង ដើម្បីឱ្យប្រជាជននៃប្រទេសទាំងពីររស់នៅក្បែរគ្នាប្រកបដោយសន្តិភាព ស្ថិរភាព និងវិបុលភាពរួម។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមអំពាវនាវសហគមន៍អាស៊ាន បន្តគាំទ្រការដោះស្រាយជម្លោះនេះដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលមានស្រាប់ និងគោលការណ៍ជាមូលដ្ឋាននៃការមិនប្រើប្រាស់កម្លាំងប្រឆាំងនឹងបូរណភាពទឹកដីនៃរដ្ឋណាមួយ ដើម្បីឱ្យសន្តិភាព និងស្ថិរភាពអាចកើតមានឡើងសម្រាប់ប្រជាជនប្រទេសទាំងពីរ តំបន់ និងសកលលោក។ យើងក៏សូមអំពាវនាវជនរួមជាតិ បន្តស្មារតីរួបរួមសាមគ្គីជាធ្លុងមួយ ដោយឈរលើព្រលឹងជាតិខ្មែរតែមួយតរៀងទៅ ចៀសវាងចាញ់ឧបាយកលនយោបាយក្រុមប្រឆាំងជ្រុលនិយម ដែលបានកំពុងបង្កើតព័ត៌មានក្លែងក្លាយ បំបែកបំបាក់សាមគ្គីជាតិ ធ្វើឱ្យប៉ះពាល់ឧត្តមប្រយោជន៍ជាតិ ជាពិសេសកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយជម្លោះព្រំដែន តាមគោលការណ៍សន្តិវិធី ឈរលើច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងនានាជាធរមាន៕

ថ្ងៃសៅរ៍ ១៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦